ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ ០២ សរណន

# សារាចរណែនាំ
# ស្តីពី
# ការកំណត់ក្របខណ្ឌមន្ត្រីរាជការស៊ីវិលតាមលក្ខន្តិកៈដោយឡែក

កន្លងមក្រសួង ស្ថាប័នបានធ្វើសមាហរណកម្មមន្ត្រីរាជការស៊ីវិលទៅតាមមុខតំណែង និងកាំប្រាក់បៀវត្សចាស់ដោយផ្ទេរបញ្ចូលទៅក្នុងក្របខណ្ឌថ្មីតាមខ្លឹមសារនៃអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ២០០១ ស្តីពីគោលការណ៍សមាហរណកម្មមន្ត្រីរាជការស៊ីវិលទៅក្នុងក្របខណ្ឌថ្មី។ ទន្ទឹមនឹងនេះ ក្រសួង ស្ថាប័នមួយចំនួនក៏បានធ្វើការតែងតាំងមន្ត្រីឱ្យចូលក្នុងក្របខណ្ឌថ្មីដែរ ប៉ុន្តែពុំទាន់បានចប់សព្វគ្រប់តាមចំនួនក្របខណ្ឌដែលបានកំណត់ក្នុងលក្ខន្តិកៈដោយឡែកនីមួយៗ និងស្របតាមទិសដៅកំណែទម្រង់រដ្ឋបាលរបស់រាជរដ្ឋាភិបាល។ ចំពោះមុខ ដើម្បីជំរុញការកំណត់ក្របខណ្ឌមន្ត្រីរាជការស៊ីវិលតាមលក្ខន្តិកៈដោយឡែកនីមួយៗឱ្យបានឆាប់រហ័ស រាជរដ្ឋាភិបាលសូមធ្វើការណែនាំ ដូចខាងក្រោម ៖

១- ក្រសួង ស្ថាប័ននីមួយៗ ត្រូវរៀបចំក្របខណ្ឌមន្ត្រីរាជការស៊ីវិលនៅក្រោមឱវាទដោយកំណត់ឱ្យបានច្បាស់លាស់នូវមន្ត្រីដែលត្រូវស្ថិតនៅក្នុងក្របខណ្ឌរដ្ឋបាលទូទៅ ក្របខណ្ឌក្រសួងមហាផ្ទៃផ្នែករដ្ឋបាលស៊ីវិល ក្របខណ្ឌ មន្ត្រីរាជការទូត ក្របខណ្ឌគ្រូបង្រៀន ក្របខណ្ឌមន្ត្រីសុខាភិបាល ក្របខណ្ឌបច្ចេកទេសទៅតាមប្រភេទ **ក ខ គ** និង **ឃ** ដែលបានបង្កើតតាមព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែក។

២- ចំពោះប្រភេទក្របខណ្ឌនីមួយៗ ក្រសួង ស្ថាប័ន ត្រូវកំណត់ឱ្យបានច្បាស់លាស់នូវមន្ត្រីដែលស្ថិតនៅក្នុងឋានន្តរស័ក្តិទី ១ ឋានន្តរស័ក្តិទី ២ និង ឋានន្តរស័ក្តិទី ៣ ទៅតាមសមាមាត្រកម្រិតអតិបរិមា ៥ភាគរយ ក្នុងឋានន្តរស័ក្តិទី ១ និង ២៥ភាគរយ ក្នុងឋានន្តរស័ក្តិទី ២ ដោយធ្វើការប្រៀបធៀបទៅនឹងចំនួនមន្ត្រីសរុបនៅក្នុងប្រភេទក្របខណ្ឌនីមួយៗ។

៣- ដើម្បីបំពេញសមាមាត្រក្នុងឋានន្តរស័ក្តិទី ១ និងទី ២ ក្រសួង ស្ថាប័ន ត្រូវធ្វើការវាយតម្លៃឱ្យបានម៉ត់ចត់បំផុត ដោយផ្អែកលើលក្ខណសម្បត្តិ និងមុខតំណែងដែលទទួលខុសត្រូវរបស់មន្ត្រីរាជការនៃក្របខណ្ឌនីមួយៗ ដោយប្រើប្រាស់ឯកសារដែលក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាលបានបោះពុម្ពធ្វើជាមូលដ្ឋាន ក្នុងការពិនិត្យ និងវាយតម្លៃ និងតាមនីតិវិធីផ្ទៃក្នុងនីមួយៗ។

៤- ក្រសួង ស្ថាប័ននីមួយៗ ត្រូវរៀបចំសេចក្តីព្រាងព្រះរាជក្រឹត្យ អនុក្រឹត្យ ឬប្រកាស ស្តីពីការកំណត់ក្របខណ្ឌមន្ត្រីរាជការស៊ីវិលតាមលក្ខន្តិកៈដោយឡែក ហើយបញ្ជូនទៅក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ដើម្បីធ្វើសុពលភាព ដោយមានការចូលរួមពីតំណាងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងសាមីក្រសួងស្ថាប័ន។

៥- ការកំណត់ក្របខណ្ឌមន្ត្រីរាជការស៊ីវិលតាមលក្ខន្តិកៈដោយឡែក ត្រូវធ្វើឡើងដោយព្រះរាជក្រឹត្យ អនុក្រឹត្យ ឬប្រកាស ឱ្យបានចប់ជាស្ថាពរនៅមុនដំណាច់ខែ មេសា ឆ្នាំ ២០០៤។ ដោយឡែកចំពោះ ក្រសួងអប់រំ យុវជន និង កីឡា ត្រូវធ្វើអោយបានចប់នៅត្រីមាសទី៣ នៃឆ្នាំ ២០០៤។

ទទួលបានសារាចរណែនាំនេះ ក្រសួង ស្ថាប័នទាំងអស់ ត្រូវសហការ និងចាត់តាំងអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ និងទទួលបានលទ្ធផលល្អប្រសើរ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូន

សម្តេចនាយករដ្ឋមន្ត្រី សូមចុះហត្ថលេខា

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**និងជាប្រធានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល**

**សុខ អាន**

**កន្លែងទទួលៈ**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- គ្រប់សាលាខេត្ត ក្រុង
- ឯកសារ-កាលប្បវត្តិ